ការសម្ភាសរបស់បងស្រីយឿន សុខនាថ

ក៏ អ្នកសម្ភាស មាសចិន្តាពិសី ខ៏ អ្នកដែលគេសម្ភាស យឿន សុខនាថ

ក៏ ជាដំបូងខ្ញុំសូមជំរាបសួរបង ខ្ញុំឈ្មោះមាសចិន្តាពិសី ខ្ញុំមកពីសកលវិទ្យាល័យព្រីហ្គ្រាមយ៉ីងហៅកាត់ថាប៊ីវ៉ាយយូនៅសហរដ្ឋអាមេរិកដើម្បីសម្ភាសជីវប្រវត្តិរបស់អ្នកមីងដើម្បីចងក្រងដល់កូនចៅជំនាន់ក្រោយអោយពួកគាត់ស្គាប់បានលឺថាពីមួយជំនាន់ទៅមួយជំនាន់មានការលំបាកអ្វីខ្លះ??ជាពិសេសនៅក្នុងសម័យពុលពតរ៉ាក៍ បងមិនទាន់សម័យពុលពតប៉ុន្តែបងអាចដឹងថាមានជីវិតសព្វថ្ងៃមានការលំបាកចឹងហាណាស់បង។។
ហើយខ្ញុំសូមបញ្ជាក់ថ្ងៃដែលខ្ញុំសម្ភាសបងនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ នៅភូមិរនាះ ឃុំកោះដាច ស្រុកជ្រោយចង្វា រាជធានីភ្នំពេញ។
ក៏ ចឹងបងមានឈ្មោះអ្វីដែរ???
ខ៏ ខ្ញុំឈ្មោះ យឿន សុខនាថ
ក៏ យឿន សុនាថ ហាបង?
ក៏ កាលពីក្មេងបងមានឈ្មោះហៅក្រៅពីនិងដែលទេ?
ខ៏ អត់ទេមានតែឈ្មោះ យឿន សុខនាថ និង។
ក៏ ចឹង អើសព្វថ្ងៃបងមានអាយុប៉ុន្ថានដែលហើយ???
ខ៏ អាយុ អើ ៣៨ឆ្នាំ ហើយ។
ក៏ អើបងអាចចាំពីឆ្នាំកំណើតរបស់បងថាកើតនៅក្នុងឆ្នាំណាដែល?
ខ៏ អើ កើតនៅឆ្នាំ១៩៧៩
ក៏ ស្ទានតែឆ្នាំ ២០៧៩ ហាហាហា។ ចឹងបាននៃថាបងកើតអត់ទាន់សម័យពុលពតទេ?
ខ៏ និង ហើយ
ក៏ ចឹងឆ្នាំខ្មែរបងឯងកើតក្នុងឆ្នាំណាដែល?
ខ៏ ឆ្នាំខ្មែរ ឆ្នាំមមែ
ក៏ ទីកន្លែងកំណើតរបស់បងនៅទីណាដែល?
ខ៏ នៅភូមិ រនះ និងស្រុកកំណើតនៅនិងអូនឯងស្គាល់ហើយណា នៅភូមិរនះ ឃុំកោះដាច ឥឡូវចូលខេត្តតាកែវ កាលមុនគេដាក់ស្រុកមុខកំពូលចឹងហាស ឥឡូវគេកាត់ចូលអ៊ីគេ??ខណ្ឌជ្រោយចង្វា ចឹងហាស
ក៏ ចឹងពីមុនបាននៃថាពីមុនគេដាក់ភូមិរនះ ឃុំកោះដាច ស្រុកមុខកំពូល ខេត្តកណ្ដាល ប៉ុន្ដែឥឡូវប្ដូរមករាជធានីភ្នំពេញ រ៉ាញ។
ខ៏ និង ហើយ
ក៏ បងមានបងប្អូនបង្កើតចំនួនប៉ុន្ថាននាក់ដែរ???
ខ៏ បងប្អូនប្រាំបួននាក់
ក៏ ខ្ញុំស្ទានតែបួននាក់។បងជាកូនទីប៉ុន្ថានក្នុងគ្រួសារ?
ខ៏ កូនទីមួយ
ក៏ អ ចឹង បងគេ
ខ៏ បង គេ
ក៏ ប្អូនរបស់បងមានឈ្មោះអ្វីខ្លះដែល?
ខ៏ ខ្ញុំឈ្មោះ យឿន សុខនាថ ប្អូនទី២ ឈ្មោះយឿន សុខនី ប្អូនទី៣ ឈ្មោះយឿន សុខណាក់ ប្អូនទី៤ ឈ្មោះយឿន សូរិយា ទី៥ យឿន ណិនហួយ
ស្រីហាស ដល់ទី៥ យឿន សាយន៍ ប្រុសដែល មួយទៀត យឿន សុខនឿន បានមួយទៀតឈ្មោះ យឿនយ៉ន
ក៏ សព្វថ្ងៃពួកគាត់ប្រកបរបរអ្វីដែល?
ខ៏ ភ្ជានរកអ៊ីទេកសិកម្មទាំងអស់ ស្រីត្បាញ ប្រុសរត់ម៉ូតូឌុប ខ្លះរកត្រីចឹងទៅក្រៅពីនិងខ្លះទៅបួសលោកចឹងទៅ
ក៏ អ មាននាក់បួសលោកទៀត ប្អូនទីប៉ុនន្ថានបួសបង?
ខ៏ ប្អូនពៅទាំងពីនុះ
ក៏ អ បួសទាំងពី
ខ៏ ចាស

ក៖ គាត់ឃ្លីសបានប៉ុន្មានវស្សាដែលហើយ??
ខ៖ គាំងពីអាយុ១២មើលឥឡូវអាយុ២០ថាម្តេចុះម្តេមួយម្តេពីរអីនិង មួយទៀតឃ្លីសអាយុគាំងពីអាយុដប់ពីរដែលតែឥឡូវវាចូលដប់ប្រាំពីរឆ្នាំដែលហើយ
ក៖ ឃ្លួនរបស់អ្នកមីងគាត់ឃ្លីសនៅវត្តណាដែល??
ខ៖ វត្តកោះដាច់យើងនិងប៉ុន្តែទៅរៀននៅវត្តស្ពឺ ឥឡូវចេញពីវត្តស្ពឺទៅរៀនវត្តជម្ពូវន៍ ឃ្លួនឯងស្គាល់ដែលតើហ៊ី?? ព្រោះអីរៀនបានលេខមួយហ៊ំ គេបញ្ជូនទៅនុះព្រោះអីសិស្សពូកែ
ក៖ ឃ្លីសហើយយើងអាចរៀនបន្តទៀតបាន?
ខ៖ និង ហើយ កាលមុនរៀននៅវត្តព្រៃកឯង ចេញពីវត្តព្រៃកឯងទៅស្គាល់លោកនៅស្ពឺហ៊ំ លោកបងមុនហ៊ា ចេញពីព្រៃកស្ពឺដល់ពេលបានលេខមួយន៎ បានទៅជម្ពូវន៍
ក៖ កាលពីក្មេងអ្នកមីងចូលចិត្តលេងអ្វីខ្លះដែលជាមួយបងឃ្លួនអ្នកមីង?
ខ៖ លេងទាក់យ៉ានធម្មតា លេងឈូស លេងមីក បន្ថែងកូនមាន់កូនទាអីនិង កាលពីក្មេងហ៊ាណា គាតាសុំទឹកហូបផងអីនិងណា ហាសហាស កាលនុះលេងទាក់ឃ្លីស លេងអាគ្ងរលេងមួយហើយ អានិងពីក្មេងវាចឹង អានិងខ្ជែរយើងពីមុនមកហ៊ាណាវាចឹង ចេះលេងតគ្នាមកលេងអីចាក់កៅស៊ូ
ខ៖ អ៉ បងអត់ចេះទេទូរស័ព្ទ ចេះតែប្រើទេបុរាណចំម៉ង
ក៖ អត់ចេះលេងFACE BOOK អីទេ
ខ៖ អត់ចេះទេ តែទូរសព្ទ៍គេចុចមកចេះតែទទួល
ក៖ ហើយចុះការងារវិញបងចូលធ្វើអ្វីជាមួយបងឃ្លួនបង?
ខ៖ និយាយទៅវល់បងគេមិនសូវបានលេងជាមួយបងឃ្លួនម៉ានទេ នៅជុំគ្នាជួយធ្វើការងារឪពុកម្តាយចឹងហ៊ាណារួចពីនិងទៅធ ំទៅធ្វើការរោងចក្រ ប៉ុន្មានឆ្នាំទៅបានចេញមកវិញបានមកក្បាញ នៅមួយគ្រួសារបានកូនពីរតែប្តីស្លាប់បាត់ហើយ មេម៉ាយតើរាល់ថ្ងៃចិញ្ចឹមកូនពីរ
ក៖ តែនៅស្អាតទៀតហ៊ាបងពេ១ហើយខ្ញុំស្មានតែម្តេជាង
ខ៖ ហាសហាស និងចាស់ផងធ្វើការរោងចក្រប៉ុន្មានឆ្នាំ
ក៖ ហេតុអីបានជាបងឈប់ធ្វើការរោងចក្រមកក្បាញចឹងវិញបង?
ខ៖ និយាយទៅធ្វើការរោងចក្រច្រើនពេកទៅវាហត់ទ្រាំ ហើយណាមួយនិយាយអោយចំទៅគឺនឹកផ្ទះ ទៅណាក៏នឹកតែផ្ទះ ចេះតែដើម្បីរកលុយ ថាអោយតែបានធូរតិចមកផ្ទះវិញហើយ បើមានកូននឹកកូនទៀត ព្រោះថាកូនអត់ឪពុកហើយ កុំអោយអត់ម្តាយទៀត ហើយបានម្តាយនៅជាមួយទៅបានអោបក្រសោបកូន ហើយដោយសារជីវភាពខ្សត់ខ្សោយទៀត ដល់ទៅពេលចឹងវាវងធ្ងរធារតិច យ៉ាយអោយចំជំនាន់នុះ ក្បាញយើងវាធ្លាក់ទឹកម៉ាសារ គ្មានទីផ្សារបិទប៉ុន្មានឆ្នាំនោះ មុខរបរយើងក៏អត់មានអ៊ីធ្វើដែលមានតែធ្វើការរោងចក្រកាលជំនាន់នុះ ឥឡូវទើបបានរាងដើបក្បាញរួចមកវិញបានបានមកធ្វើវិញនិង
ក៖ ក្បាញកេក្បាញ្ជរបៀបម៉ិចដែលបង??
ខ៖ គេក្បាញ្ជហ្ហ ជាមួង យើងនិងពិនគ្រាន់ថាឥឡូវវាងគ្រាន់បើជាងពីមុនពីមុនអត់មានទីផ្សារ ធ្លាក់ទឹកម៉ាសាដូចអត់មានទីផ្សារអត់ឈ្ងួញទិញចឹងហ៊ាក៏អត់បានថ្លៃសីសូត្រសំពាត់ពិនដល់ឥឡូវវាមានវិញ
ក៖ ហ្ហ ជាមួងនិងប៉ុន្មានថ្ងៃដែលបងអាចក្បាញបានហើយមួយ
ខ៖ និយាយ ទៅអានេះសូត្រចាក់សូត្រៀបើប្រឹងបានប្រាំថ្ងៃ បើយើងប្រើតាមកម្លាំងមួយអាទិត្យអានិងសូត្រចាក់សូត្រហាសៀ បើសូត្រចាក់អ៊ំបោះនោះតែបីបួនថ្ងៃអីទេ អានុះវាក្ឍិត ម្ភៃរៀលជាង ម្ភៃពីរម្ភៃបីវាចុះមុនចិតសិបតែចិតសិបនិងក្ឍិតក៏ថ្លៃដែលចាក់បានតែប្រាំក្ឍិតអីទេ នៅផ្ទៃយើងទៀត ផ្ទៃយើងនិងមួយរយហាដែល ក្បាញ្ជចឹងទៅបានថ្លៃតែអានេះក៏វាថ្លៃដែ

ល អានោះគ្រាន់តែសូត្រថ្លែតែវាចាក់អំបោះ នាំគ្នាកិតតាមនិងទៅ
ក៏ ក្បាញនិងតើគេត្រូវការសម្ភារៈអីគេខ្លះដែល??
ខ៏ សម្ភារៈដូចជា ធ្នេញ ក្រប ហើយយើងជួលគេមួល អស់ជិតមួយរយដែលគ្រាន់តែឡើងកីនិងហាស បើយើងអន្ទនបីក្រលីអស់ប្លនរយហាហើយ រួចនៅយើងអាចាក់មួយគ្រលីមួយរយហា មួយគ្រលីមួយរយហា បីគ្រលីនិងយើងអន្ទនបានសាបសិបប្រាំបីកៀ្ងតហាស មែនដូចសូត្រចាក់យើង បើសូត្រចាក់យើងអស់ប្រាំបីគ្រលីទៀតសរុបទាំងអស់ដប់មួយគ្រលី វាស្មើនិងមួយពាន់ប្រាំរយដុល្លារហើយណាស់ នៅម៉ានេះទៀត នៅមួយគ្រលីមួយរយហាទៀតវាស្មើនិងមួយពាន់ប្រាំមួយរយហា អានិងគិតទាំងអន្ទនហាហើយនៅចូលមួយរយទៀត យើង វាស្មើជិតពីរពាន់ហ៑ យើងលក់បានមួយកៀ្ងនជិតសិប ដប់ក្បៀ្ងនវាមិនប្រាំពីររយ
 រួចនៅប្រាំបីក្បៀ្ងនទៀតយើងគិតតាមនិងទៅ តាំងពីខែប្រាំពីរឥឡូវខែប្រាំពីរ ខែប្រាំបីអីហើយ ប៉ុនយើងមិនមែនក្បាញ្ជ តែវាណាយើងរត់ពីរកី ព្រោះកូនអត់ទាន់ចូលរៀនហ៑ បើសិនទាំងវាយើងគិតថាវាអត់ដល់ពីរឆ្នាំទេ ក្បាញ្ជតាមកម្លាំងល្ហមនិងមួយឆ្នាំនិងបើយើងផាត់ទៅវាបានខ្ទង់មួយពាន់
ក៏ បានច្រើនណាស់ដែល
ខ៏ ហត់ណាស់មីអូនអើយ បានមួយឆ្នាំប្រើងណាស់អូនណាស់ ប៉ុន្តែយើងអត់សូវហត់ម៉ានទេ អានិងគេវាយតាមនិងមួយគ្រលី បើអានោះអន្ទនបានម្ភៃប្រាំក្បៀ្ងន មួយគ្រលីបានតែដប់ក្បៀ្ងនជាងទេ ខុសគ្នាតិច អានេះវាអន្ទនបានតិច វាខុសគ្នាខ្លឹងណាអូន តែជីវភាពឥឡូវវាបានក្បាញ្ជចឹងវាវាងធ្ងជាងមុន អ្នកនៅកោះដាច់ក្បាញ្ជសងលុយរដ្ឋ ប្តីរកគ្រីរកអីចឹងទៅណាមីអូន ដល់ពេលឥឡូវទឹកឡើងប៉ុន្ថានឆ្នាំនោះមានបានរកអីណានាក់ខ្លះទៅធ្វើសំណង់បាត់ទៅ ទើបឥឡូវទេស្រីនៅក្បាញ្ជ នៅផ្ទះមើលខុសត្រូវកូនចៅអីចឹងទៅ ប្តីចេញទៅរកទៅកោះដាច់ស្ងួត មានតែក្បាញ្ជ មានធ្វើស្រែណាបើអត់ដី ព្រោះអីទឹកវាពាត់ជុំវិញ ឆ្នាំនិងវាមានទឹកចូលបឹងក្រែងស្រកទៅវិញមានត្រីទៅវាមិនចាំបាច់រកទៅវាធ្ង បានក្បាញ្ជទៅវាងធ្ងតិចតែអត់ក្បាញ្ជទៀតនិងចប់ហើយ
បើធ្វើការអីវាពិបាក បើស្រុកគេមានចំការ មានអីទៅ មួយរយៈអត់មានអីធ្វើនិងគេរត់ចោលកូន ពិបាកដែលនិងម្នាក់មើលខុសត្រូវទៅវាអត់ពិបាកកូនចៅដែលនិងហាស
ក៏ ម្តាយណាដែលចង់ទៅចោលកូន

ខ៖ និងហើយ ពីមុនមានដែលធ្វើការរោងចក្រណា បានស្គាល់គេចោលកូនមួយរយៈដែលប្តីធ្វើសំណង់ ដល់ពេលមានក្បាញ ក្បាញនៅផ្ទះចឹងទៅ ប្តីចេះតែធ្វើការលិចកើតអីចឹងទៅបានមើលខុសត្រូវកូនអីចឹងទៅ
ក៖ ចឹងបានស្នេហ៍ជាមួយ បានជុំគ្រួសារ
ខ៖ និងហើយ
ក៖ ឪពុក ម្តាយរបស់បងគាត់មានឈ្មោះអ្វីខ្លះដែល???
ខ៖ ចក់ យ៉ៀន ម្តាយឈ្មោះ
ក៖ ឪពុករបស់អ្នកមីងគាត់មានអាយុប៉ុន្មានដែលហើយ??
ខ៖ ពុកចូល ៦០ជាងម៉ែចូល៦០ជាងដែលហើយ
ក៖ អ្នកមីងទីកន្លែងកំណើតរបស់ឪពុកម្តាយអ្នកមីងនៅទីណាដែល??
ខ៖ គាត់ហេម៉ែនៅស្រុកនឹង ស្រុកសំរោងអណ្តែត
ក៖ នៅខេត្តណាដែលអ្នកមីង?
ខ៖ អត់ស្គាល់ដែល តែគាត់ចេញពីស្រុកសំរោងអណ្តែតមកនៅអន្លង់ផ្លែង នៅក្រោយព្រែកអញ្ចាញ មិនសូវស្គាល់ដែលតែដឹងតែស្រុកអន្លង់ផ្លែង តាំងដាច់អាពាតគាត់មកនៅនិងរហូតបានមកចាប់ដៃម៉ែមមកនៅនិងរហូត
ក៖ ចឹង ឪពុកអ្នកមីងគាត់ធ្លាប់បានបួសដែរ??
ខ៖ ឪពុកធ្លាប់បានបួសដែល តែកូនគាត់ក៏បួសដែលក្រោយមកបានកូនពីរកូនគាត់ក៏បួសដែល ក្រោយទីពីរទីបីនោះបួសទាំងពីរដែល បើនិយាយអោយសប់ទៅផ្ទះនិងសុទ្ធតែលោកហាសហាស មិនម៉ែនអោយបួសទេតែសុទ្ធតែទារបួសទៀត និស្ស័យមកបួស កូនបងវិញ្ញសំពោះសុំបួសទាំងអាយុប្រាំបីឆ្នាំ អង្វរបួសរហូតដល់ដប់ពីរឆ្នាំ តែឥឡូវចង់ប៉ុនម្តាយ សុំបួសទាំងពួរាងទ្រើសជាងនិងតិច
ក៖ កាលពីអ្នកមីងនៅក្មេងធ្លាប់បានជួយធ្វើការងារអ្វីខ្លះដល់ឪពុកម្តាយ??
ខ៖ ធ្វើនំបញ្ចុកដឹកអោយជុំវិញកោះ
ក៖ ដឹកនំបញ្ចុកដើរលក់ម៉ែនរឹក៏ដើរបោះអោយម្ហូយ??
ខ៖ ដឹកអោយម្ហូយ និងដាក់ក្ងោដើរលក់ខ្លះទៅ ព្រោះអីប្អូនរៀនប្អូនស្រីរៀនទាំងអស់ ម៉ែពុកនោះធ្វើទៅព្រោះនំបញ្ចុកដាក់ស្ករដាក់អោយម្ហូយ ជួនកាលដួលកំពុកអស់រលីងខែភ្លៀងហ៊ានអ៊ីលកាលនុះដល់ពេលមានហ្ស្រាំងណាចាប់កាលនុះមានកង់ណាទំនើបៗកង់ខ្ជែរនិងដល់ចឹងទៅជួនកាលចុះអត់ទាន់រអិលទៅកំពុកអស់រលីង បើម្ហូយនំបញ្ចុកត្រីខាតអត់អីទេណា តែបើសម្ហូក្រលីវិញប្រាំស្ករដូចយកទៅអោម្ហូយម្តង គេដាក់ឈើយើងកង់មិនដាក់ឈើចឹង រួចយើងដាក់ស្ករខាងនេះមួយ

ខាងនោះមួយ ដល់ឈើមួយទៀតដាក់អញ្ចេកប្រាំល្ងីដាក់អោយម៉ូយជួនកាលដល់ជួនកាលអត់ដល់កំពុកអស់រលីង
ក៏ កំពុកទាំងអស់??
ខ៏ និងហើយ ចុះជំនាន់នុះផ្លូវមានដូចផ្លូវយើងឥឡូវណា ផ្លូវដីកំពុកទាំងអស់ជួនកាលទៅចូកយកមកបានចាក់ចោលទៅប៉ុនយើងនៅសល់លិចកើតអីចឹងហាណាសល់ចឹង
ក៏ កិតទៅកំសត់ហើយសប្បាយទៀត
ខ៏ និងហើយ អូយនឿយណាស់អូនណាទូលអូសមួយថ្ងៃដប់ប៉ាច់ក្ងន្ល ចាប់នំបញ្ចុកដៃឥឡូវមែនសុទ្ធតែម៉ាសុ៊ីនណាមុនមិនផាត់ដៃអាឈើរួចដៃសុអស់ហើយជាមួយអាក្បឿងហ៉ ជួនកាលម៉ែគាត់ក្ងនខ្ចីទៅគាត់ដាំបាយអោយប្អូនៗទៅរៀនទៅ ដល់ពេលគាត់រឹងមាំទៅគាត់ជួយធ្វើទៅ បើយើងជួយធ្វើទាំងឪពុកផងម្តាយផង ដល់ឪពុកឡើង គាត់អត់ចង់ពឹងគេហត់ណាស់អូនអើយដល់យប់ម៉ោង១ម៉ោង២ជិតភ្លឺអីចឹងទៅអ៊ ពេលចូលឆ្នាំ ភ្ជុំអីចឹងទៅក្រោកជាន់ទាំងម៉ោង១ម៉ោង២យប់ ដើម្បីព្រឹកឡើង
រួចតែគេទិញដល់ពេលល្ងាចម៉ូយកម្ជង់ច្រើនហ៉ាអត់ស្គាល់ស ម្រាកអីនិងគេទេព្រោះផ្ទះគេគេអត់ធ្វើទេចូលឆ្នាំហ៉ ផ្ទះបងគ្មានបានសប្បាយអីទេចូលឆ្នាំ ព្រោះផ្ទះបងធ្វើនំបញ្ចុកលួងគេម៉ូយហ៉ាទាំងអស់បើបងធ្វើមួលគេអោយធ្វើតើរាល់ថ្ងៃតែបងរត់រាអត់រួចព្រោះមួយថ្ងៃកិនមួយថ្ងៃ ក្រៅពីម៉ូយពុកវេនគេបីបួននាក់ចឹងទៅគេចែកលំលែកគ្នាធ្វើបើពុកមួយថ្ងៃមួយនាក់
ដល់ចឹងមួលលើគាត់ទាំងអស់ ម៉ូយគេតែប្រាំពីរប្រាំបីអីតែម៉ូយបងវិញសាបសែសិបល្ងី ជុំវិញកោះមិនធម្ម្ជាណាម៉ូយ ព្រោះគាត់ធ្វើល្ងចឹងជួនកាលបើវេនគេនំបញ្ចុកដល់ថ្ងៃអត់ទាន់ទេខ្ជូចហើយ យកតែត្រឹមដប់បីគីឡូអីទេ បើវេនបងវិញដប់ប្រាំបីគីឡូ ម្ភៃគីឡូ បើសិនសល់អាចទុកដល់ព្រឹកទៀតក៏អត់ខ្ជូចដែលព្រោះគាត់ធ្វើល្ង គាត់ហាប់គាត់ជាន់អីអោយយូរហាសដល់ពេលចឹងនំបញ្ចុកគាត់ធ្វើល្ងជាងគេ គាត់ដូចថាសូម្បីតែអង្ករវើសមើលចឹងហា អង្ករខ្លះបាយទន់ខ្លះបាយអត់ឡើងធ្វើទៅខ្ជូចជួនកាលម្ជ្ជាហើមអីចឹងធ្វើទៅខ្ជូច ដល់ពេលបងហត់នឿយពេក ម៉ូយច្រើនដល់ហត់ពេកឈប់ធ្វើទៅធ្វើការរោងចក្រវិញទៅណា សល់ន្ទានម៉ែពុកធ្វើទៅរត់អត់រួចគាត់ចេះជុំរុះៗទៅ ដូចថាគេចេះធ្វើម៉ាសីនម៉ាជ់នាខាងនោះគេចូលមកពុករត់អត់រួច ដល់ចូលយូរៗទៅម៉ូយក៏កាន់តែខ្ជីតទៅ គេធ្វើម៉ាសីនវារាងល្ងហា រ៉ាស្ងិតហា ដល់ទៅចឹងទៅគាត់រត់អត់រួចគាត់ខ្ជិលណាមួយរកលុយធ្វើផ្ទះធ្វើសំបែងគាត់ឈប់ទៅ

បើគាត់ធ្វើម៉ាសីនកាលនុះក៏គាត់អត់បានធ្វើផ្ទះដែលពេលធ្វើម៉ាសីនដូចគេហាដល់ចឹងទៅគាត់រើផ្ទះគាត់ឈប់ធ្វើនំបញ្ចុកទៅ កូនធ្វើការរោងចក្រ ក្បាញនៅផ្ទះ ហត់ណាស់អ្នកអើយហត់ណាស់ស្ថានេះអីប្រហែលនៅកំពង់ទូលផង ឡើងប្រាំងផង បើគេម៉ាសីនគេធ្ងរគេអត់សូវប្រើកម្លាំងទេណា គេចុចម៉ាសីនបងប្រើកម្លាំងសុទ្ធ ចឹងយ៉ាប់កម្លាំង៖៖
ក៖ ឪពុករបស់បង គាត់ស្លូតរឹក៏កាច គាត់ដែលវាយកូនចៅអីដែលទេ??
ខ៖ រាងកាចដែល តែដល់ពេលឥឡូវគាត់ចូលសីលចូលអីគាត់ទម្លាក់ហើយពុកគាត់កាចដែលនុះហាសបើគាត់នឿយ ក្រមានអ្នកស្លូត ព្រោះធ្វើហត់ណាស់ម្នាក់ៗ គាត់ខឹងកូនស្រីនោះ ឈ្ងងឈ្ងាងៗ
 គាត់ធ្វើៗទៅៗតែគាត់កាច ឪពុកក្មេកនោះវិញគាត់អត់ធ្វើ ហើយកាចទៀត កាចណាស់ដូចហ៊ុនសែនចឹងគេហៅគាត់តែតាសើងទេ
គាត់ធ្វើការនៅគុកព្រៃស ប៉ូលិសហាស ពិនគ្រាន់ថាគាត់កាចពេលគាត់ចូលផ្ទះគាត់ប្រដៅកូនចៅ ប្រពន្ធកូន
និយាយចឹងចេះតែចូលសាច់រឿង បិនគាត់គាត់កាចអត់ដូចឪពុកយើងហាសគាត់ធ្វើ តានុះគាត់កាចគាត់អត់ធ្វើទេគាត់ខាងបញ្ជារ ហាសហាសហាស៖
ក៖ ចឹងគាត់ចាំតែណែនាំគេ គាត់អត់ធ្វើ??
ខ៖ និង ហើយបើថាប្រដៅវិញ អោយប្រពន្ធបត់ជើងចាំស្តាប់ បើប្រដៅចិត្តអោយប្រពន្ធក្រោកទៅ គាត់គងថ្ងាស អោយប្រពន្ធឡើងប្រេបស្លឹក គាត់អង្គុយបញ្ជារលើកអាចម៍គោអោយកាប់អ្ងុសអីចឹងទៅណា និងនិយាយៗៗចូលសាច់រឿងនិយាយដើមឪពុកក្មេងហើយចង់និយាយតិចទៀតថាម៉ែក្មេងគាត់នឿយមែន តែឪពុកក្មេងគាត់មិនសូវជានឿយទេ ពិនបើថាម៉ែពុកនេះគាត់នឿយតែនឿយទាំងប្តីទាំងប្រពន្ធ គាត់ធ្វើណាស់កូនច្រើន រកបាកដៃទទេបានផ្ទះចិញ្ចឹមប្រាំបីប្រាំបួននិងឃើញអត់ ម៉ែបងឥឡូវគាត់មិនសូវនឿយទេគាត់នៅតែផ្ទះ មានប្រពន្ធកូនណាចង់នៅផ្ទះទេ គាត់កាចចុះកាលមុនគាត់ធ្វើការមន្ត្រីរាជការចឹង កូនចេះតែនៅទៅណាពិនបើគាត់នៅផ្ទះកូនចែកជើងគ្នា ហាសហាសហាពិនគ្រាន់ថាគាត់ចែកជើងគ្នាគេមានមុខរបរនៅភ្នំពេញ កូននៅអត់សូវបានគាត់កាចពេក។។
ក៖ គាត់ឧស្សាហ៍និយាយប្រាប់កូនច្រើនពេក។។
ខ៖ ចាស បើថាប្រដៅវិញគ្មានអ្នកជិតខាងណាដេកបានទេ មយយទល់ភ្លឺអីន៏ ហាហាហា។

ក៏ ស្ត្រីរាប្រាប្រដៅម៉ងនិងហាស់
ខ៏ ការអនុវត្តមិនសូវជាមានទេ តែអាខាងទ្រីស្ដីវិញទៅសិនហើយ ហាហាហា
លេខមួយម៉ងណាពិនតឡូវគាត់មិនសូវកាចទេគាត់រាងវង្វេងគាត់ដើរចុះដើរឡើង សុំគេមួយរយពីររយអីចឹងទៅ បើអូនឯងទិញតវ៉ាន់វិញ អ៊ីទៅណានុះអើទៅភ្នំពេញ
អ៊ីឯងទៅភ្នំពេញធ្វើអីស្ដាប់អត់បានផង គាត់ស្ដាប់បានតែមានដឹងថាគាត់វង្វេងណា ហើយគាត់ថាទៅបើកលុយទៅកន្លែងធ្វើការទៅបើកលុយ គាត់មានបើកលុយណាបើគាត់អាត្រេតហើយនុះ ជួនកាលគាត់ធ្លាក់ដល់កប់ស្រូវហ៊ា បាត់ ពីរបីថ្ងៃបងប្អូនគេដើរកឡើងវង្វេង ពិនតឡូវគាត់រៀងគ្រាន់បើ ហើយពីមុនវិញកូនចៅទៅនិយាយសួរនាំអីនិយាយបានពីរបីម៉ាត់គាត់ទៅនិយាយអីផ្សេង កាលពីមុនកូនចៅមានបានធ្វើអីចាំតែការពារគាត់និង ខ្លាចគាត់ដើរទៅណាគាត់ចេះតែដើរទៅនុះទៀតហាស់ អើកូនៗគាត់សុទ្ធតស្រីៗកូនស្រីគាត់ពីរនាក់ប្រុសប្រាំនាក់ ពិនសុទ្ធតែស្ដេចទ្រីស្ដីហើយ
ឪពុកក្មេកខ្ញុំស្រីជ្រើនទៀត៖
ក៏ ចុះម្ដាយរបស់បងស្រីវិញ គាត់ស្លូតក៏កាចដែល??
ខ៏ ម៉ែ"ខ្ញុំគាត់ស្លូតតើ
តែឪពុកមុនដំបូងគាត់កាចតែតឡូវគាត់ចូលសីលអស់ហើយ ៖៖
ក៏ កាលពីបងនៅក្មេង ឪពុកម្ដាយរបស់បងគាត់ធ្លាប់បានប្រាប់សាច់រឿងប្រវត្ដិ៍របស់គាត់អោយបងស្ដាប់ដែលទេ??
ខ៏ ប្រវត្ដិ៍ហ៊ា និងហើយគាត់និយាយដែលតើនិយាយពីជំនាន់ពល ពតដែលតើ ពិបាកក្ដានមួយក្ដានពីរអីចឹងហ៊ា
ប្រវត្ដិគាត់ជូរជត់ណាស់ប្រវត្ដិដូចតាខាងឪពុកខ្ញុំហាស់គាត់ស្លាប់នៅជំនាន់ពលពត
ដល់ពេលបងប្អូនឪពុកខ្ញុំស្លាប់នៅពល ពតដែល តាចក់ខ្ញុំវិញនិងពុកខ្ញុំនិយាយហា អេតាខ្ញុំឈ្លោះតាយួន
ត្រកូលគាត់ចក់ ពិនមិនមែនគាត់យួនទេណា គាត់ឈ្លោះតាយួនហាហា ដល់ចឹងគាត់រាយមងគាត់ឃ្លានហ៊ា ដល់គាត់ឃ្លានទៅគាត់យកត្រីទៅស្ងោរនៅកំសៀវ
តាធ្វើអីនិងអាពត ដើរមកឃើញត្រីហ៊ាយកគាត់ទៅសម្លាប់
ដល់ប្អូនគាត់ក្មេងដែលអាយុប្រហែលប្រាំមួយឆ្នាំ
ដូចថាដើរទៅឃើញអាដូងគេ គគេសីហ៊ាទៅគគេទៅដល់មានអ្នករាយការណ៍ ក្មេងពិននិងទៅឡើងកាប់ដូងកើតដែលហើយកប់ក្ដាទាំងរស់ដាក់ដូងពីលើ ហើយក៏ស្លាប់ទៅនិងអស់ឪពុកមួយម្ដាយមួយ ហើយឪពុកគាត់កូនពៅគាត់ថ្ងៃដែលគេកប់ត្រាប់ប៉ែកហ៊ក៏រត់ទៅចូលត្រសុក ផុតតែកាំជណ្ដើរមួយ លែងត្រាប់ឆេះហើយឆេះផ្ទះអស់រលីងម៉ងហើយងាប់អាមេជ្រូកមួយវាដូចមកវងជំនួសចឹងហ៊ាងាប់ឥងនៅកាំជណ្ដើរនិង ស្លាប់អស់មេជ្រូកមួយទៅគ្រាន់តែរងពីយាយ
បងពុកគាត់ទាញចូលត្រងសុក ស្លាប់បីនាក់ឪពុកមួយប្អូនមួយហើយនិងបងគេបង្ហស់មួយ បងពុកគេយកមកធ្វើក្រដបនៅកោះដាច់នឹងហ៊ាតែបាត់ដំណឹងឈឹងរហូតមកក្ដានដឹងយកទៅសម្លាប់យកទៅអីបើគេយកមកកោះដាច់បាត់ដំណឹងមានតែស្លាប់ទេ

ព្រោះអីមុនដំបូងគេកុហកថាយកមកធ្វើការណ្ណតនៅកោះដាច់និងហ៊ានៅអាពត
និងបងគាត់មួយប្អូនគាត់មួយឪពុកគាត់មួយស្លាប់នៅជំនាន់ពល ពតគាត់ធ្លាប់និយាយប្រាប់ចឹងនិងអស់បីនាក់ខាងគាត់ខាងពុកម៉ែវិញអត់អីទេនៅទាំងអស់បងប្អូនម៉ែមានតែបីនាក់ទេនិងតែស្រី បើខាងពុកដូចយាយចឹងស្លាប់អស់បីនាក់ចឹងហ៊ានអាពត៖៖
ក៖ ច្រើនដែល??
ខ៖ កុំអីមួយពួជ អាពេលទម្លាក់គ្រាប់បែកមកទាញរត់ចូលត្រងសុកទាន់តើម៉ែ
ពោះនៅតែថ្ងៃកើតប្អូនពៅគាត់នោះកុំអីស្លាប់មួយពួជនិងជំនាន់អាពត៖៖
ក៖ ចុះជីដូនជីតាខាងម្តាយរបស់បងបងស្គាល់ឈ្មោះគាត់អត់???
ខ៖ អត់
អត់សូវស្គាល់ផងព្រោះកើតអត់សូវទាន់ បើថាខាងយាយបង្កើតស្គាល់ជីដូនជីតាទៀតអត់ស្គាល់ ស្គាល់តែលោកយាយសនតាមុំចឹងហ៊ានខាងម្តាយ បើខាងឪពុកវិញឈ្មោះតាយួនហើយនិងយាយនាងខ្មែរទេប៉ុន្តែឈ្មោះយួនហាហាហាចុះលីគាត់ឈ្មោះតាយួនៗចឹងចេះតែហៅតាមទៅតែត្រកូលគាត់ឈ្មោះចក់យួន
ចក់និងជីតាគាត់ទេ៖៖
ក៖ ចុះបងកើតទាន់ពួកគាត់ដែលទេ??
ខ៖ និយាយទៅស្គាល់តែ.....អត់ទាន់តែគាទេលីគាត់និយាយប្រវត្តិអោយស្តាប់និងហ៊ាម៉ាក់យាយនៅទាន់ យាយតាខាងម្តាយខ្ញុំក៏ទាន់ដែលតែគាត់ទើបស្លាប់ឃ្លានដប់ឆ្នាំនិងប្រហែលជាម្ភៃឆ្នាំនិងយាយបើតាប្រហែលជាដប់ឆ្នាំជាងអីនិងចឹងហ៊ាណានិងទាន់គាត់ចឹង គាត់ស្លាប់និងឯងជិតក្រមុំអស់ហើយ៖៖
ក៖ តែបងដឹងសាច់រឿងច្រើន៖៖
ខ៖ និងហើយដឹងដោយសារគាត់និយាយសាច់រឿងអោយស្តាប់ ម៉ែអាចុងក្រោយនេះ....កុំតែគេមករំដោះទាន់ គេយកគៀងទៅអស់ហើយនិងនៅតែតិចទៀតអស់ដាច់ពួជគេប្រុងតែយកទៅហើយនុងដល់ពេលចឹងទទួលគេមករំដោះទាន់ក៏នៅដល់សព្វថ្ងៃនិងទៅ គេតម្រង់ជួរណាហៅគៀងគងអស់ហើយ៖៖
ក៖ គាត់ធ្លាប់ប្រាប់បងថា ពេលគេគៀងគងយកទៅសម្លាប់និងម្តងប៉ុន្ថានៗនាក់ដែល??
ខ៖ និយាយទៅទល់តែគាត់បានគាត់ដឹង បងមិនសូវដឹងទេរឿងសម្លាប់និងជារឿងរបស់គេវាមិនដឹងម្តងប៉ុន្ថានៗនាក់យើងមិនសូវដឹងដែលណា គ្រាន់ដឹងថាពាក់ពន្ធ័និងតាបង្កើតពូបង្កើតអ៊ុំបង្កើតយើងនិងគាត់ដឹងតើអ្នកដែលរាយការណ៍ថាដាំបេះដូងក្មេងទូចគ្នាទៅគកេសីនោះដូងគ្នាទៅចេះកាប់អី ដល់ចឹងយកគ្នាទៅកប់ទាំងរស់ដាក់គ្នាប្រកាច់ក៏ដឹងដែលបើពុកគាត់ឈរមើល តែបើយើងសម្លាប់ទៅសម្លាប់មកវាចេះតគ្នាចឹងអត់ចង់ តែបើយើងសងសឹកសម្លាប់អាអ្នករាយការណ៍និងកូនអាអ្នករាយការណ៍និងសម្លាប់តគ្នាទៀតចឹងខ្ជិលត្រឹមនិងទៅអ្នកណាសងអីអ្នកនិងទទួលទៅ ក្មេងប៉ុននឹងទៅកាប់អីកើតគេយើញចឹងក៏យកគ្នាទៅកប់ទាំងរស់ដាក់រណ្ដៅដាក់ដូងពីលើលុបដីទៅទុកធ្វើជីម៉ងបើក្ងងនុងគ្នាទម្រាំដាច់ខ្យល់ដាប់ដឹងលំបាកយ៉ាងណាជំនាន់អាពតចឹង៖៖
ក៖ ចឹងក្រុមគ្រួសារបងរស់នៅខេត្តកណ្ដាលនេះអស់រយៈពេលយូរហើយមែនទេ??
ខ៖ យូរហើយទាំងពីជិតសិបជ្រាំបួនមកដល់ឥឡូវអត់ផ្លាក់ប្តូរទៅណាផង៖៖
ក៖ ផ្ទះអីអត់ផ្លាក់ប្តូរទេ??
ខ៖ អត់ អត់ផ្លាក់ប្តូរទេនៅនិងរហូត៖៖
ក៖ តាំងពីមកបែកមកនៅទីនិងរហូត??
ខ៖ ទាំងគ្រួសារប្តីខ្ញុំនៅជិតនិងផ្ទះជាប់គ្នានិងដែល៖
ក៖ ចុះបងមានបងប្អូនឬសាច់ញាតិណាដែលគាត់រស់នៅក្រៅប្រទេសដែលទេ??
ខ៖ អត់មានផង អត់មាននៅក្រៅប្រទេសទេមានតែនៅនិងទាំងអស់៖៖
ក៖ នៅភ្ជាញទាំងអស់គ្នា?
ខ៖ និងហើយនិយាយទៅមុខរបរសាមញ្ញៗប្អូនមានប្រពន្ធនៅស្រុកនោះក៏ធ្វើស្រូវ
ប្អូនៗៗទៀតរាល់ថ្ងៃរត់ម៉ូតូឌុប
ប្អូនប្រុសមួយទៀតបួសតែប៉ុននិងទេស្រីៗការងារសាមញ្ញធម្មតាទេ៖៖
ក៖ ចុះដែលជីវិតរបស់បងឬក៏ស្វាមីរបស់បងគាត់មានឈ្មោះអីដែល???
ខ៖ ឈ្មោះអើ សឿតពន្លក៖៖

ក៖ គាត់មានអាយុប៉ុន្មានដែលបង??
ខ៖អាយុអើ៣៩បងមួយឆ្នាំ៖៖
ក៖ កាលដែលបងរៀបការនិងនៅក្នុងឆ្នាំណាដែល??
ខ៖ ការនិងដូចនៅឆ្នាំមើលដូចជា២០០១ឬក៏២០០២អីនឹងភ្លេចបាត់ហើយនេះ ព្រោះអីក្មួនមើលឆ្នាំ២០០២មកអូនកើត២០០៣យើងពាពោះមួយឆ្នាំហ៊ានចឹងក្នុង២០០០ព្រោះអីយើងការភ្លាមៗមានភ្លាមចឹងកូននិងវាកើតមក២០០៣ចឹងការក្នុង២០០២៖៖
ក៖ រៀបការនិងម្តាយឪពុកជាអ្នកផ្សំផ្គុំអោយដល់បងមែន??
ខ៖ និងហើយជាអ្នកផ្សំផ្គុំ៖៖
ក៖ចឹង ពេលនិងមានថ្លៃដំនួនអីដែលទេ??
ខ៖ មានតើ
ក៖ មានច្រើនដែលទេបង??
ខ៖ កាលនុះបានត្រឹម៥០០ព្រោះអីកាលនុងមួយតូតែ១២០០០ម៉ឺនទេដំនាន់នុងហ៊ាត្រឹម៥០០អីទេសាមញ្ញៗបើគេអ្នកធូរធារមានមែនទែនអានុងត្រ០០ឬ៨០០អីល្ហើយត្រឹម៥០០អីអានិងល្មមគួរសមហើយព្រោះអីខាងប្តីអ្នកខ្វះខាតដូចយើងដែលធ្វើនំបញ្ចកមុខរបរដូចគ្នាហ៊ាហ៊ាមិនទៅអ្នកមានអ្នកធូរធារអីទេ អ្នកមធ្យម៖៖
ក៖ មូលហេតុអីបានជាបងបានជួនជាមួយនិងបងប្រុសដែល??
ខ៖ ចាស និយាយទៅអ្នកធ្វើនំបញ្ចកជាមួយគ្នាពិនដូចថាវាមិនទាន់មានចិត្តស្រលាញ់គ្នា ដល់យើងធ្វើការរោងចក្រគាត់រត់ម៉ូតូឌុបហ៊ា ចេះតែប្រអាប់ចុះឡើងៗៗ ទៅក៏បាត់ចិត្តស្រលាញ់គ្នាទៅតែប៉ុននិងព្រោះអីប្រអាប់ថាចង់បានអ្នកនេះអ្នកនោះអីចឹងទៅណា ប្រអាប់ទេដំបូងចេះតែលេងសើចទៅគេនោះគេគូរផ្ទងបងប្អូនគេយើងគូរផ្ទងបងប្អូនយើងទៅ បើអ្នកស្រលាញ់ផ្សេងទៀតគេចេះតែប្រអាប់លិចប្រអាប់កើតទៅដល់ចឹងទៅមានចិត្ត ក៏ចូលដណ្តឹងតែអាចូលដណ្តឹងនិងក៏មានអ្នកប្រជែងគ្នាដែល អាឯងនេះគេយករូបថតទៅគេចង់បានគេយកបងប្អូនគេមកហើយ នេះក៏ម៉ែគេពេញចិត្តនោះ ក៏ពេញចិត្តនិយាយនេះឯងពីរគេពីរដែលចង់និយាយថាគេនោះបងប្អូនគេមិត្តភក្ដិគេអ្នកគូរផ្ទងទៅចឹងហ៊ានគេបាត់ចិត្តស្រលាញ់យើង គេចង់បានយើងមុខពុកយករូបថតទៅយកបងប្អូនគេមកហើយ ឯនេះមកយប់មកថ្ងៃហ៊ាហ៊ាហ៊ាគេថាដល់ក្មួណាព្រោះពេលនិងយល់សប្តិឃើញអ្នកចង់បាននិងរាងទាបដែលយល់សប្តិឃើញពស់ខ្លីនិងមករុំជើងហ៊ាស់ហើយធាក់អាពស់និងចេញទៅមានអាពស់វែងមួយទៀតធ់មករុំដែលទាញអត់ចេញសោះជាប់នូវនិងទៅហ៊ាហ៊ាហ៊ាទាញវាទៅក្បាលវាវ៉ីតតែមករុំយើង អានិងអ្នកដែលអត់ដែលជួបមិនដឹងទេតែខ្ញុំជួបបើប្តីខ្ញុំធ្លាប់យល់សប្តិឃើញម្តងដែល កាលនៅរាប់អានគ្នាហ៊ាមកខ៉ាដល់ខ៉ាទៅគេយកកាបិតកាប់ដាច់ក្បាល អត់ស្តីរកគ្នាជិត៣ឆ្នាំហ៊ាហ៊ាហើយដល់ពេលគេចូលដណ្តឹងយល់សប្តិឃើញចឹងម្តងទៀតហ៊ា និងទៅលេងរួចម៉ងហ៊ាហ៊ាហ៊ាអាចថាគ្រូក៏ថាបានដែលណាក៏នេះទៅព្រោះថាអ្នកចង់បាននិងរាងទាបដែលដល់អាពេលពស់និងវាទាបដែលដល់អាប្តីយើងខ្ពស់ហើយយល់សប្តិឃើញពស់និងវែងទៀតបើទៅនោះជាប់មានទៅរួចណានោះក៏មិនបាននេះក៏មិនបានហើយនេះគេចង់សួរដល់សមុ៊ីខ្លួនទៀតដល់ហើយក៏ឪពុកម្តាយចូលស្តីដណ្តឹងពេញច្បាប់ជាផ្លូវការចឹងទៅណា យើងវាដល់គ្នា ហើយខ្ញុំអត់ដឹងទេណាំព្រោះពួកនិងវានិយាយថា ខាងនេះទៅរកគ្រូទាយថាមើលការណាវ៉ាដល់គ្នា ហើយគេថាគ្នានិងអត់នៅឆ្ងាយទេនៅជិតៗៗនិងឆ្នាំក្រោយសល់គ្នាហើយតែលើកអាច់ហ៊ាហ៊ាហ៊ាចឹងហ៊ាបងដឹងសាច់រឿងតែប៉ុននិងទេណា៖៖
ក៖ កាលពីបងរៀបការនិងបងមានអាយុប៉ុន្មានដែល??
ខ៖ អាយុ២៤ ប្តី២៥៖៖
ក៖ ភាគច្រើនខ្ញុំឃើញគេរៀបការអាយុ១៨ឬ១៩អីមិចបងយូរមេស???
ខ៖
 និយាយទៅដល់ក្មួយម្តងហើយ១៦តែអត់ទាន់ចេះស្រលាញ់គេចង់បានតែអាយុ១៦ដល់ពេលនៅៗៗដល់អាយុ២៤ ២៤និងអត់ទាន់ចង់យកទៀត កុំតែអ្នកៗវាធ់ទាន់ច្រើនហ៊ាក៏យកទៅ៖៖
ក៖ ខ្លាចអ្នកការមុនបងទៅពិបាកទៀត ហ៊ាហ៊ាហ៊ា៖៖

ខៈ ចេះតែខ្លាចទៅណា

យើញពុកម៉ែកាចហើយចឹងចេះតែខ្លាចទៅណា ចេះតែអត់ទាន់ចេះស្រលាញ់ប្រុសចឹងអត់ចង់ទេ

តែដល់ពេលវាដល់គូហើយយើងកេចទៅណាទៀត ពិននិងហើយអត់ចង់នៅវារែកទៀត ពិនគ្រាន់ថានិយាយអោយចំទៅបើចាស់ៗគេមើលផងទៅគេថាម្ដុំនិងលោកតាជួ្ជ វល់ចង ចងក្រមុំៗទុកហាថា មិចបានចងទុក

ចងទុកហើយព្រោះពេលសែនម្ដងៗលោកតាឆាន់មិនទាន់ផងក្មេងៗមកដណ្ដើមខ្ជិច

ចងវាទុកដល់ថាប្រលេងទៅក្រមុំៗការប្រដាស់គ្នាដូចខ្សែង លោកតាចងអត់អោយម្ដុំនិងយកប្ដីទេ ទៅចាស់ថាគ្នាក្មេងទេគ្នាអត់ដឹងអីទេប្រលេងទៅ អោយគេមានគូមានស្រករទៅ

ខឹងណាស់ៗអោយតែគេសែនព្រេនអីលោកតាឆាន់អត់ទាន់ទេដណ្ដើមរបស់លោកតាខ្ជិចរកតែហិតក្លិនអីតិចមិនទាន់ទេហាហា

លីចាស់ៗ២ឬ៣នាក់និយាយថាទៅមើលណាទេសគាត់ចងដឹងមិចក្រមុំៗម្ដុំនិងអត់ទាន់មានគូផ្លូងនៅជ្រកហ៉ាអត់អោយវាយកប្ដីទេចងវាទុកហាហា

តែពិតមិនពិតខ្ញុំអត់ដឹងទេចាស់ៗគាត់និយាយហ៉ា គាត់ថាក្រមុំៗនៅម្ដុំនិងចងទុកអត់អោយមានប្ដីទេ អោយនៅអោយយូរតិច ហាហាហា៕៚

កៈ កាលបងនៅពីក្មេង ភាសាខ្មែរយើងបងចេះអាច ចេះសរសេរបានល្អដែលទេ??

ខៈ

អឺម បានតិចតួចទេអូនអើយ បើប្អូនៗបានគេរៀនបានគ្រាន់បើបានទី៨ទី៩ទី១០អីបើបងបានតែទី៣ទេ

ជីវភាពបងដូចថាយើញស្រាប់ហើយបងប្អូនវាច្រើនរួចយើងធ្វើរកដោយកម្លាំង

អត់មានអីថាបើបានពុកម៉ែមានអីណាបើបែកពីជំនាន់ពលពតមកបាតដៃទទេនិង គាត់មកខាងពុកបានគោកណ្ដុរកន្លាតមួយ ដីកេរម្ដាយទុកអោយបាតដៃទទេសុទ្ធ ពីអាពតមកគាត់គៀងាបាតអង្ករនិងពោតទំពោតអីជំនាន់នុះពុកនៅខ្សត់ខ្សោយហ៎មិនទាន់មានរកធ្វើអីបាន៕៚

កៈ កាលពីបងរៀនទី៣និងបងរៀននៅសាលាណាដែរបង??

ខៈ រៀននៅសាលាកោះដាច់យើងនិង

ដល់ចូលទី៤ឈប់រៀនបណ្ដោយ ព្រោះអីម៉ែពោះធំកូនខ្ចីមានរកអីបានណា ហើយយើងធ្វើការមិចកើតទល់តែយើងឈប់រៀនទៅយើងមើលការងារគាត់ គាត់ធ្វើអត់កើតរកអត់កើតពោះធំកូនខ្ចីហើយពេលនិងជីវភាពយើងវាមានទាន់បានធូរធារណា ទល់តែអ្វើនំបញ្ចុកបោះមួយទៅបានមានលុយកាស ទិញអង្ករទិញក្របីយកមកដើម្បីផ្គត់ផ្គង់គ្រួសារ មិនដូចឥឡូវមានត្បាញមានរវៃអីណាជំនាន់នុះជំនាន់នុះសម្បូរតែអ្នកធ្វើស្រែធ្វើស្រូវនំបញ្ចុកអីចឹងយកទៅលក់នៅឯភ្នំពេញចឹងទៅ ជិះកាណូតទេកាលនុះទល់តែបងធំហើយមានមួយមានអីនៅហ៎ ហើយជំនាន់នុះគាត់រែកមួយរែកៗយកទៅលក់នៅភ្នំពេញដូរអង្ករពីភ្នំពេញមកទេដាក់ទូកកាណូតគេជិះតាមនិងជំនាន់នុះអត់ទាន់មានស្ពានជ្រោយចង្វាធ្វើទេណាកំសត់ហ៉ាណាស់អូន ដល់ថ្នាក់ជិះកាណូតទៅជូនកាលជិះទាន់ជូនកាលអត់ទាន់ឡើងពេញៗសម្បូរអ្នកធ្វើនំបញ្ចុកណាស់ ជូនកាលគាត់រែកជូនកាលកាណូតចេញចោលគាត់រែកអង្ករតាំងពីភ្នំពេញមកដល់និង រែកអង្ករហ៉ាដល់ពេលហើយគាត់តែងហូបអីតិចតួចហើយព្រោះគាត់ហត់នឿយហើយប្រើកម្លាំងហ៉ាទល់ល្ងាចបានគាត់រែកមកដល់ផ្ទះរែកធូន់ហ៉ាណាប៉ុនៗនៃល្អិ មិនជម្នូតាទេណារែកទៅរែកមកពីភ្នំពេញជំនាន់នុះគាត់លំបាកណាស់

រួចគិតមើលជំនាន់នុះគាត់រែកដីចាក់ផងអីផងនិយាយទៅគាត់ប្រើកម្លាំងម៉ងហ៉ាមិនមែនដូចក្មេងៗឥឡូវមិនដូចជំនាន់គាត់ទេណានិយាយអោយចំទៅពុកគាត់តែម្ដងនិងនឿយហាតែប្រើកម្លាំងអត់ទាន់ស្រណុកទេឥឡូវនិងហាសនៅតែរពីសរពីកដៃនិង គាត់អត់ទំនេរទេ៕៚

កៈ ពេលដែលបងទៅរៀននិងបងធ្លាប់មានលុយចាយទៅរៀនអត់បង??

ខៈ

ជូនកាលមានជូនកាលអត់ ជំនាន់នោះចាយក្រដាសប្រាំកាក់ក្រដាសមួយរៀលនិ

ង ជួនកាលអត់ចេះហូបបាយ ព្រឹកៗទេនោះជួនកាលទៅៗទិញដំឡងចៀន អត់ហានស៊ីអស់ខ្លួនឯងទេទុកអោយអ្នកនៅផ្ទះអ្នករត់ទទួលចឹងអោយអ្នកនៅ
និងហើយជួនកាលមកដល់ម៉ែដាំបាយទាន់ទៅបានស៊ីជួនកាលឃ្លានខ្លាំងយំធាក់ដីចឹងទៅណា បើឃ្លានច្រើនតែចាស់ៗគាត់និយាយថាខ្ចីតអស់ដីអាញ់ឃ្លងអស់ខ្ចីតអស់ដើមសន្ទាន់អាញ់ ដរបើឃ្លានមកដល់បាយឆ្អិនទៅស៊ីទៅចុះក្មេងឃ្លានហាមានសួរចេះគិតអីមកដល់ឃ្លានខ្លាំងព្រោះជាប់រវល់រវាញនំបញ្ចកអីចឹងទៅរវល់ជួនកាលគេក្មេងៗដូចបងដែលគេទៅរៀនជួនកាលគេបានហូបបាយកកពីផ្ទះទៅ
យើងវិញអត់ស្ងរនេះអត់ឃ្លានទេ តែបបរទៅមកវិញអត់ស្ងរមានអីស៊ីឃ្លានជ្រុលស្ពាននិងអត់ទាន់មានអីស៊ីនោះចេញអាចរកកាចនិងមកយំធាក់ដីជួនកាលយកក្បាលបោកនិងដីទៀតហាស់យំឃ្លានហាហាហាកាចណាស់ដែលហាស៖៖
ក៖
 មកដល់ពេលឥឡូវបងនៅតែមានមិត្តភក្តិដែលធ្លាប់រៀនជាមួយគ្នាទៀតអត់??
ខ៖
 និយាយទៅមិត្តភក្តិនិងវាសឹងតែអត់មានផង ព្រោះអីគេសុទ្ធតែរៀនជ្រៅៗជាងយើង បើណាមួយយើងរៀនបានត្រឹមថ្នាក់ទី៣និងមានទៅទាន់ចេះរាប់អានមិត្តភក្តិណាតែមានមិត្តភក្តិនៅជាប់ផ្ទះអ៊ីនិងបើថាមិត្តភក្តិមួយនោះគេបានប្តីធ្វើក្រូការងារទៅហើយដល់ពេលចឹងមីមួយនោះគេបានធ្វើក្រូទៅគេមានខ្សែគេធ្វើក្រូនោះមិត្តភក្តិនៅព្រែកអញ្ចញ្ចាគេធ្វើក្រូនិងមិត្តភក្តិដែល ហើយចេះនិយាយលេងទៅថាគេន៎គេបានធ្វើក្រូដល់ហើយនិយាយអ៊ីនិងហើយមកពីប្រញ្ជាប់យកប្តីពេកចេះបង្ហាប់គ្នាលេងគ្នាមានទាន់ចង់បានប្តីណាឈប់រៀនទាំងពីថ្នាក់ទី៣មេសនុះដល់ពេលគ្នាយកប្តី២៤ឆ្នាំហើយនុះហាហាហាចេះបង្ហាប់គ្នាលេងជួនគ្នាកាលធ្វើការរោងចក្រន៎ដល់ហើយជួបគ្នាគេទៅស៊ីអីនៅងមុខរោងចក្រនោះដល់ហើយនិយាយគ្នាធាងឯងន៎គេបានធ្វើក្រូហ៊ានធ្វើក្រូទាំងប្តីទាំងប្រពន្ធប្តីស្អាតទៀតហាសបើវាអត់ស្ងរស្អាតទេ៖៖
ក៖ អាស្ងរដូចបងថា ឈប់រៀនការប្តីទៅចាំថាទៅអត់ អានេះឈប់យូរហើយនិងហ៎ា៖៖
ខ៖ នុះហើយ ដល់ហើយថានិងហើយហែងឆាប់យកប្តីពេក
 អើចឹងក៏ចឹងទៅណាបើយើងជួបគ្នាបានមួយភ្លែតណាយើងចេញពីរោងចក្រមកហូបបាយ គេមកពីណាទេមកហូបបាយដែលនិងក៏មកជួបគ្នាទៅរួចក៏និយាយសំណេះសំណាលគ្នាតិចតួចទៅណា អានិងពួកម្តាយគេធ្លាប់នៅនិងហើយអ្លាប់តស៊ូមួយគ្នាដើរទៅរៀនចឹងទៅណា គេទៅនៅព្រែកអញ្ចាញ្ចុះឪពុកគេគ្រូនិយាយទៅគ្រូ
ប៉ុន្តែមិនដឹងថាគ្រូខាងអីទេណា
ដល់ចឹងគេមិនគ្រូទៀត បើឪពុកគេគ្រូស្រាប់ហើយ៖៖
ក៖ ឪពុកគ្រូហើយកូនក៏គ្រូទៀត៖៖
ខ៖ និស្ស័យរយើងមិនស្ងរមានអ្នកធ្វើការអីផង និយាយទៅនិស្ស័យសាមញ្ញៗ
ដូចពុកអីគាត់ធ្លាប់នៅស្រុកធ្វើស្ងរធ្វើស្រែនៅចំការ
ហើយគាត់សុខចិត្តមកយកម៉ែនៅភ្នំពេញ ចង់ចេញពីធ្វើស្ងរធ្វើស្រែ ព្រោះអីព្រោះគាត់ធ្វើឆ្អែតហើយ គាត់អត់ចង់ធ្វើទៀតទេ ចឹងទៅគាត់យកប្រពន្ធស្រុកទន្លេអោយបានឈប់ពីធ្វើស្ងរគាត់មកធ្វើឆ្អើធ្វើត្រី បើបងកើតមកមិនដែលធ្វើស្ងរយ៉ាងមិចផងនិង ហាហាហាក្បាញ្ធ្វើនំបញ្ចកធ្វើរោងចក្រអីចឹងទៅណា៖៖
ក៖
 ចុះនៅក្នុងជីវិតរបស់បងដែលធ្លាប់ទៅស៊ីឈ្នួលគេយកកម្រៃមកជួយផ្គត់ផ្គង់ក្រុមគ្រួសារដែលទេ??
ខ៖ ធ្លាប់ធ្វើរោងចក្រ
ក៖ ធ្លាប់ធ្វើតែរោងចក្រតែមួយនិងទេ???
ខ៖ លក់នំបញ្ចក ការងារយើងនិងក្នុងផ្ទះចឹងទៅណា លក់នំបញ្ចកនៅក្នុងផ្ទះយកលុយអោយម៉ែមកផ្គត់ផ្គង់គ្រួសារចឹងទៅណាព្រឹកៗទៅណា
ជួនកាលស្ពាននិងមកដល់ជួនកាលស្ពាននិងអត់ដល់ទេ យើងលក់ទៅត្រឡប់មកត្រឡប់មកមួយកញ្ចេជុំវិញកោះនិងហាស
ប៉ុនយើងគ្រាន់ថាយើងចេញចូលចេញចូលហ៎ា៖៖

ក៏
 ជីវិតរបស់បងតាំងពីក្មេងមកដល់ពេលឥឡូវនេះ មានការផ្លាស់ប្តូរអីគេខ្លះដែលបង??
ខ៏ អត់នៅតែប៉ុននិងបើរាល់ថ្ងៃនិងប្រឹងធ្វើប្រឹងក្បាញ្ញនិងក៏រកលុយចង់អោយកូនរៀនមិនទាន់ដែល កូនរៀននឹងនិយាយទៅយើងអយ់មានប្តីរកបន្ទុកដូចគេ
យើងបើមានប្តីជាបន្ទុកទៅវាអាចធូរខ្លះ ហើយបងតែម្នាក់ឯងក្បាញ្ញចឹងហ៉ាសងមួយផងយើងអោយកូនទៅរៀនផងហើយយកលុយរដ្ឋផង
និយាយទៅមុនបងក្បាញ្ញនេះ បងធ្លាប់លក់ចាប់ហួយដែលចេញពីរោងចក្រមកលក់ចាប់ហួយនៅមុខនឹងដល់យើងលក់អត់មានចំណូលបញ្ជូលនោះយើងចេះតែនេះដេញតុងតិនទៅខ្ទះនេះខ្ទះនោះទៅយកលុយរដ្ឋទៅ
 មួយអ្នកជំពាក់តិចតួចអីដល់យើងអត់មានអីដាក់បញ្ជូលមិនជំពាក់គេមកដល់ឥឡូវក្បាញ្ញផងដោះគេផងសងលុយរដ្ឋផង
ហើយនឹងជំពាក់គេខ្ទះខាតចងការចងអីគេចេះតែដោះស្រាយទៅណាសងផ្ទៃគេខ្លះទៅសងរដ្ឋខ្លះទៅ អើរកូនរៀនខ្លះទៅព្រោះយើងធ្វើបុណ្យធ្វើទានខ្លះចងដៃគេខ្លះទៅដល់ពេលចឹងចំណូលយើងវាតិច
ចំណាយវាច្រើនចឹងបងរត់អត់ចងរួចទេ គេមានប្តីទៅគេចេះតែជួយទប់គ្នាទៅណាប៉ុននិងនៅជាមួយឪពុកម្តាយបើកាលមុនធ្លាប់ចេញទៅនៅជាមួយប្តី១ឆ្នាំ២ឆ្នាំដែលដល់យើងចូលមកវិញវាមិនដូចយើងនៅក្នុងបន្ទុកតែម្តងទេ
យើងត្រូវការទុកដាក់ខ្លួនឯងដែលខ្លះដើម្បីកូនយើងមិនអាចទៅពឹងម្តាយបានទេ គាត់កូនទ្រើសៗអស់ហើយនៅក្នុងនុងវាមានម្ហូនមានអីអាញ្ជ៉ើអាញ្ជ៉ាកខ្លះដែលដល់ពេលចឹងគាត់មិនសួរសិខជាមួយយើងយើងក៏មិនសួរសុខជាមួយគាត់ដែលដែលប៉ុនគ្រាន់ថាយើងពឹងពាក់គាត់សិនទៅណា
 ប្រោះយើងនៅខ្សត់ខ្សោយ បើពេលយើងចេញពីប្តីយើងមានដើមណាធ្វើរកណាអត់ទេ កាលបានប្តីនោះមានជីវិភាពណាធូរធារចែកធ្វើដើមរកស៊ីណាអត់ទេ
យើងធ្វើក្បាញ្ញចឹងទៅយកលុយមួយចឹង
ប្តីនោះ្ុកលុយរដ្ឋ៥០០ទិញម្ហូតូជ៏ៈទៅគ្រោះថ្នាក់ជាក់ស្តា គ្រោះថ្នាក់ជិតងាប់ជិតរស់ទៀត ចឹងជីវិភាពវាដូចអត់មានធូរតែម្តងនៅហ៉ាវាតឹងហាដល់ពេលមានកូនមានដីចឹងទៅកូនឈឺកូនអីចឹងទៅវាតែងតែមានខ្វះខាតហើយ
បើគេគេមានឪពុកម្តាយគេ ការហើយគេមានដើមរកស៊ីចឹងទៅគេអាចធ្វើរួចដល់យើងអត់ផងនឹងចាប់ដៃគ្នាមកជាតដៃទេ ជាតដៃទេទោះគាត់ចែកគ្រាក់គាត់អត់អោយលក់ចែកដីគាត់ទុកអោយកូនចៅនៅ២០ម៉ែត្រទេមិនច្រើនទេ ដល់ទៅពេលយើងបែកជាក់ប្តីនោះយើងមិនមកនៅជាមួយគាត់វិញ
មានទាន់បានធូរណាបើកូននៅរៀន មិនទាន់បានធូរទេ
បានថាឃើញតែចឹងទេប៉ុន្តែមិនមែនជាអ្នកធូរធារអីទេហាហាខ្សត់ខ្សោយបើនិយាយអោយចំទៅវាមុខមិនរួច៖៖
ក៏ កាលពីបងនៅក្មេងនិងបងថ្លាប់រើសម្ហូបដែលទេឬក៏ទល់តែសាច់បានបងញ៉ាំ
ុអី???
ខ៏
 និយាយទៅបន្ណែអីមិនសួរជាប៉ុនអីទេចូលចិត្តសាច់ដល់ពេលចឹងឧស្សាហ៍ឡើងជាតិអាស៊ីតកើនិងហើយអត់សួរចេះហូបបន្ណែនោះ
សុខភាពមិនសួរល្អទេបើយើងហូបសាច់នោះតែឡើងស្ពឹកដៃស្ពឹកជើងទៅរកពេទ្យ
គេអត់អោយហូបសាច់ទេអោយហូបត្រីនិងហូបបន្ណែចឹងទៅណាតែបន្ណែត្រូវមុខដែលបានហូប
និយាយអោយចំកាលពីមុនមិនចំណូលហូបបន្ណែតែម្តងទើបតែចេះធ្វើការរោងចក្រអីនិងចេះអត់ចេះទ្រាំចេះឃ្លានទៅគ្រាន់ចេះបន្ណែខ្លះបើរួចឥឡូវគ្រាន់បើពីចេះតែសាច់ទេតមកវាល់ថ្ងៃនិងក៏មិនសួរជាបន្ណែទេចឹងសុខភាពមិនល្អមិនប្រពៃប៉ុន្ណានទេ៖៖
ក៏
 កាលពីបងនៅក្មេងចឹងបងចូលចិត្តស្តាប់បទចម្រៀងអីរ៉ាអីដែលចូលចិត្តអត់??
?

ខ៖ ចូលចិត្តធម្មតាឥឡូវកាលនៅក្រមុំអីខ្ចាស់អៀនប៉ុន្តែឥឡូវមិនសូវទេភាពមកចេះលេងចេះសើចចេះសប្បាយអីច្រើនតិចហហានិយាយទៅកាលនៅក្រមុំខ្ចាស់មានប្ដីទៅអៀនដល់បែកពីប្ដីទៅនៅខូចចិត្តដល់ពាលឥឡូវលេងខូចចិត្តទៀតហើយប្រឹងរកលុយអោយកូនរៀន រាល់ថ្ងៃនិងចូលចិត្តសប្បាយច្រើនឥឡូវចូលចិត្តលេងសើចច្រើនព្រោះពិបាកមកវាច្រើនមកហើយណាចឹងចូលចិត្តយករឿងសប្បាយៗដាក់ខ្លួន ព្រោះអីរាល់ថ្ងៃប្រឹងយកលុយអោយកូនរៀន គិតតែប៉ុននិងបានហើយគិតអនាគតយើងខ្លួនឯងបើទំនេរគេហៅលេងសប្បាយទៅក៏ទៅលេងទៅធម្មតាចឹងទៅក្នុងស្រុកក្នុងភូមិណាគេសប្បាយចឹងទៅ៖៖
ក៖ ចឹងបងគ្រួសារបងមានសមាជិកណាដែលគាត់ចេះលេងឧបករណ៍ភ្លេងខ្មែរដែលទេ??
ខ៖ អត់និងហើយ បើផ្ទះយេស៊ូនេះមានគេបង្រៀនចឹងហាស៖៖
ក៖ ចឹងបងផ្ទះរបស់បងកាលពីសម័យមុនមានលក្ខណៈបែបណាដែល??
ខ៖ ពីមុនផ្ទះបងមួយខ្នងធម្មតាទេណាប្រក្ស្លីកចឹងស្លីកនិងហើយបងនោះនៅពីក្នេងមានបងប្អូនពីនាក់ណាធ្លាប់ធ្លាក់ពីលើផ្ទះ អាពាងទឹកប៉ុននិងចុះឃ្លានហ៎ារួចម៉ែបុកគ្រឿងពុកទៅដីកគោទៅផ្ទៀងអាទឹកពាងនិងរួចផ្ទះមិនទាន់រាយជញ្ជាំងក្រោយទេ ដល់ពេលអាពាងប្រហុកយើងប៉ុនៗនិងកាលនុះមិនជំនាន់រែកទឹកដាក់ពាងមិនទាន់ទំនើបឯណាទឹកដល់ផ្ទះចឹងណាមិនរែកពីកំពុងមកដល់ទៅពេលស្រែកទៅទាញទៅធ្លាក់ពីលើផ្ទះៗនៅក្រោមមិនថ្មធ្លាក់ប៉ែកក្បាលហូរឈាមរួចអាពាងនិងទៅពីលើទៀតសន្ធប់២យប់២ថ្ងៃនិងហើយសន្ធប់២យប់២ថ្ងៃថាមិនរស់ផងតែពេទ្យនិងនិងមាននិស្ស័យស្រលាញ់ដែលតាប្រាប់ប្រពន្ធឧកទើគេស្រលាញ់ដែលគេថាមាននិស្ស័យហាពុកខ្ញុំគាត់អត់អោយពុកថាមានកូនពីរបើថាស្រលាញ់ទុកលើដៃគាត់ចឹងហ៎ាសន្ធប់២យប់២ថ្ងៃអូនស្នាមដេរនិងរយះក្បាលនិងធ្លាក់ពីលើផ្ទះផ្ទះមួយខ្នងខ្ពស់ដែលនិងហើយមួយខ្នងធ្លាក់មកចំថ្ពល់ពាងធ្លាក់ទៅពីលើទៀតជួសជីតងាប់ជីតរស់ហ៎សន្ធប់២យប់២ថ្ងៃដេកនៅពេទ្យកាលម៉ែត្រនិងនៅក្នេងនិយាយទៅក្បាលនិងរយះផងបើអានេះដេរ៖៖
ក៖ តាំងពីបងក្នេងមកដល់ពេលឥឡូវនេះបងមានបានជំនាញអីពីម្ដាយបងដែល??
ខ៖ និងជំនាញក្បាញនិងនំបញ្ចុកបើធ្វើការរោងចក្រយើងផ្សេងទៀតនិងធ្វើការរោងចក្រនិងតាមមុខងាររបស់យើងទៅបើថាមុខរបរចេញពីម្ដាយឪពុកមកមានតែក្បាញ្ជារវ៉ៃ៖៖
ក៖ កាលពីបងនៅក្នេងបងធ្លាប់មានក្ដីស្រមៃអីដែលទេ??
ខ៖ និយាយទៅអត់បានស្រមៃអីទេបើថាលក់នំបញ្ចុកហត់នឿយពេកឃើញគេធ្វើការរោងចក្រចង់ធ្វើដល់ទៅពេលចេញទៅធ្វើទៅដីវ៉ែតវ៉ាចេះតស៊ូហើយតែតស៊ូបែកផ្ទះបេកស់ប៉ែងចេះតែនឹកផ្ទះនឹកតែស្រុកៗៗនឹកតែបងប្អូនកាលនៅផ្ទះហត់នឿយចេះតែចង់ធ្វើការរោងចក្រតែគ្រាន់ថាស្រមើស្រមៃតិចទៀតដូចជាអត់បានស្រមើស្រមៃគិតអីទេគិតតែធ្វើមិចបានលុយអោយប្អូនរៀនតែប៉ុននិងគិតតែពីអនាគតប្អូនៗ៖៖
ក៖ ចឹងបងមានអីផ្ដាំផ្ញើដល់កូនចៅជំនាន់ក្រោយអោយគាត់ធ្វើមិចៗៗដែលទេ??
ខ៖ អ៎
 អោយតស៊ូខំប្រឹងរៀនសូតទៅព្រោះអីប្រទេសជាតិឥឡូវជឿនលឿនណាស់អោយប្អូនៗបើមានសម្ភតាពរៀនសូត្រអោយបានយល់ដឹងជ្រៅជ្រះកុំដូចបងទៅណាៗមិនរួចទេណាអូនណាគ្រាន់ផ្ដាំចឹងអោយជំនាន់ក្រោយ២ទៀតប្រឹងរៀនប្រឹងសូត្រទៅអោយយល់ដឹងដុចប្អូនឯងចឹងហ៎ាបានការងារធ្វើចឹងទៅវាធ្ងរដែលដួចបងបងនឿយបងហត់ណាស់នឿយណាស់មើលដៃជើងដូចប្រុសចឹងកាប់អុសទ្ទូលឡើងទំពែកៗៗក្បាលដល់ថ្នាក់ដាក់អុសអង្គុយយ៉ាងហ៎ាស់ធ្ងន់ពេកធ្វើនំបញ្ចុកនឹងក៏មិនធ្ងរដែលម្សៀទ្ទូលស្រែកសែងដល់កំពុងនំបញ្ចុករាប់គីឡូទ្ទូលមិនស្ទួលទេនឿយណាស់បានមានគំនិតធ្វើការរោងចក្រប្រហែលធ្ងរបើចេញធ្វើវាធ្ងរតែអារម្ម៉ណ៍និងនឹកតែផ្ទះធ្លាប់នៅផ្ទះយើងចេញដើរទៅណ៎ាចឹងបានផ្ដាំទៅប្អូនៗជំនាន់ក្រោយអោយប្រឹងឡើងសម័យឥឡូវទំនើបៗណាស់មិនដូចជំនាន់បងទេធំឡើងធ្វើតែនំបញ្ចុកទាំងគេទាំងយើងណាហត់ណាស់នឿយណាស់៖៖៖